● តំបន់វ៉ែនហ័រ/គ័នសេរឈើង : តៃវ៉ាន់ - គឺភូមិកំណើតថ្មីរបស់យើង

ម្តាយៈ ខ្ញុំមកពីប្រទេសចិនតំបន់ Hubei
ជាំក្មេងស្រីក្រមុះម្នាក់ដែលរស់នៅទីក្រុងតូចមួយ
មានគ្រួសារដ៏មានសុភមង្គលយ៉ាងខ្លាំងណាស់។ នៅភូមិកំណើតអត់ទីកន្លែងអូរអ៊ែរ
អត់មានទីប្រជុំជនឬទឹកសមុទ្រនិងស្ពានឥណ្ឌូរ គឺមានតែវាលស្រែព័ណ៌បៃតងខៀវខ្ចី
និងមានទន្លេហើយនិងអ្នកភូមិរស់នៅបែបសាមញ្ញៗ។
កូនៈ យើងខ្ញុំមកពីទីប្រទេសតៃតំបន់វ៉ែនហ័រនៃកុមារ
មានគ្រួសារដ៏មានសុភមង្គលយ៉ាងខ្លាំងណាស់ នៅក្នុងផ្ទះខ្ញុំមាន២នាក់កូន១គូរសំណព្វចិត្ត
នៅទៅនេះជាដងផ្លូវមួយ មើលទៅហាក់ដូចអ៊ូរអ៊ែរណាស់។ មានព្រះវិហារភ្នំនាគរាជ
អាគារក្រហមស៊ីរមិន ឆីងនៀនសួនច្បារ ផ្លូវស៊ីរហ័រ មានអាគារបុរាណ
គេពេញនិយមនៅក្នុងទីក្រុង នៅទីនេះគឺជាកន្លែងកំណើតនៃកំណើនសេដ្ឋកិច្ចរបស់ពួកខ្ញុំ។
ម្តាយៈ កាលពីនៅក្មេងៗបីឡុកបីឡូរភាគច្រើនមិនចំណាយលុយកាក់ឡើយ ដូចជាៈ
លេងបោះគ្រែះ លេងទាត់សី លេងមឹក។ល។ ហើយក៏មិនសូវមាននំចំនីអ្វីញុំាច្រើនទេ
មានតែនៅចូលឆ្នាំចិនទើបមាននំចំនីឬស្ករបស់ឆ្ងាញ់ៗបានញុំា។
ពិព្រោះតែឪពុកម្តាយរបស់ខ្ញុំបានផ្តល់នូវក្តីស្រលាញ់ពេញៗមកលើកូនៗ
នៅពេលនោះខ្ញុំគ្រាន់តែមានគោលបំណងចង់ឆាប់រហ័សធំធាត់
បានទៅធ្វើការងារដើម្បីរកប្រាក់មកចិញ្ចឹមខ្លួនឯង អាចលើកស្ទួយឪពុកម្តាយខ្ញុំធូរធារបន្តិច។
ខ្ញុំធំឡើងបានទៅគ័ងជូវទៅធ្វើការងារ
បានដំណើរការ១ឆ្នាំក្រោយមកខ្ញុំបានបញ្ចប់ការងារ
រៀបការជាមួយស្វាមីទៅរស់នៅលើកោះតៃវ៉ាន ទៅរស់នៅផ្ទះថ្មីមានភាពមិនសូវទំលាប់
ប្រឈរមុខនឹងបរិស្ថានខ្ញុំមិនដឹងធ្វើយ៉ាងដូចម្តេច
ក៏ប៉ុន្តែឪពុកក្មេកម្តាតក្មេកនិងគ្រួសារធ្វើល្អចំពោះខ្ញុំណាស់
ធ្វើអោយខ្ញុំធូរចិត្តបន្តិចហាក់ដូចដកដុំថ្មដ៏ធំចេញចឹង។ មករស់នៅតៃវ៉ាន់១ឆ្នាំកន្លងមក

ខ្ញុំមានផ្ទៃពោះសំរាលកូនបានបុត្រធីតា១ បន្ទាប់មកប្រញាប់មានកូនបុត្រាដ៏សង្ហារ១ទៀត ធ្វើអោយជីវិតរស់នៅកាន់តែមាននៃឡើងរស់នៅយ៉ាងរមាញ៉ឹកបន្តិច។

កូនៈ ពួកខ្ញុំជារៀងរាល់ដងចូលចិត្តលេងសម្តែងដើរជាតួរ សម្តែងដើរតួររួមផ្តុំជាមួយគ្នា ឬលេងរៀបផ្លូងគំនូរ។ល។

នៅអាគារវ៉នហ័រនៃអន្តោប្រវេសន៍មានកម្មវធីបានបង្រៀនបណ្តុះបណ្តាលពួកគាត់ជាចំរុះជាច្រើន ហាក់ដូចជាថ្ងៃវ៉ាកងធំបានបង្រៀនជំរំប្រព័ន្ធ e

កម្មវិធីមាតានិងកុមារនៅក្រៅតំបន់សារធាណៈកំសាន្ត

ការតាំងពិព័រណ៍ឥណ្ឌូនេស៊ីសារីរិកធាតុល។ល។ នៅទីនេះខ្ញុំបានស្គាល់មិត្តភិក្តិជាច្រើន ហើយក៏បានរៀនចេះចំណេះវប្បធម៍និមួយៗជាច្រើន

ការផ្តល់ប្រយោជន៍នៅទីនេះធ្វើអោយមានភាពសុភមង្គលណាស់។

ម្តាយៈ ខ្ញុំបានមករស់នៅតៃវ៉ាន់បាន១១ឆ្នាំហើយ។

បងស្រីៈ ខ្ញុំរស់នៅតំបន់វ៉នហ័រ១0ឆ្នាំហើយ។

ប្អូនប្រុសៈ ខ្ញុំរស់នៅតំបន់វ៉នហ័រ៨ឆ្នាំហើយ។

រួមជាមួយគ្នាឆ្លើយៈ យើងខ្ញុំស្រលាញ់លើទឹកដីតៃវ៉ាន់ណាស់ ហើយក៏ចូលចិត្តប្រពៃណីចិននឹងណាស់ផងដែរ ឬវប្បធម៍ម្ហូបអាហារនិងភាសានិយាយសេរីប្រទេសតៃវ៉ាន់ខ្ញុំស្រលាញ់អ្នកណាស់!